មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ចំនួន០២រូប ដែលបានផ្តល់ថវិកា និងតុ កៅអី ជូនដល់សាលារៀន នៅស្រុកមេសាង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **SHINOHARA Katsuhiro** ឯកអគ្គរាជទូតជប៉ុន ប្រចាំប្រទេសកម្ពុជា បានផ្តល់ថវិកា ចំនួន ៤៩.៩៦០ ដុល្លារអាមេរិក ក្នុងការដឹកជញ្ជូន កៅអី តុ ពីប្រទេសជប៉ុន មកប្រទេសកម្ពុជា

២-លោក **TATENO Junzo** ប្រធានក្រុមប្រឹក្សាអប់រំទីក្រុង **OSAKA** បានផ្តល់ តុ កៅអី ចំនួន ១.៦០០ កំប្លេ ដែលមានតម្លៃស្មើនឹង ៤៨.០០០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៨០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ និង ក្រុមជំនួយ ដែលបានរួមគ្នាផ្តល់ថវិកាចំនួន ៥៣.៦៣៤,៧០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ អំពីថ្មប្រក់ក្បឿង មានបំពាក់គ្រឿងសម្ភារៈគ្រប់បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ អណ្តូងទឹក០១ និងតារាងបាល់ទះ-បាល់ទាត់ ជូនដល់អនុវិទ្យាល័យកូនគ្រី ស្ថិតនៅភូមិកូនគ្រី ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-អង្គការយុទ្ធនាការកំចាត់មីនកម្ពុជា Cambodia Mines-remove Campaign (CMC)
២-ក្រុមជំនួយថវិកាកសាងសមិទ្ធផល SASEBO JUNIOR CHAMBER Inc.

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១៨១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកា តាមរយៈអង្គការ **School Aid Japan** ក្នុងការជួយកសាងអគារសិក្សា ជូនដល់សាលាបឋមសិក្សា នៅស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

១-លោក **HIRABAYASHI YOSHI HISA** បានផ្តល់ថវិកាចំនួន ៣២.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ ជូនដល់សាលាបឋមសិក្សារូងជ្រៃ ស្ថិតនៅភូមិរូងជ្រៃ ឃុំរូងជ្រៃ ។

២-លោកស្រី **YURI TAKANO** បានផ្តល់ថវិកាចំនួន ៥២.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សាប៉ោយតាសេក ស្ថិតនៅភូមិប៉ោយតាសេក ឃុំបឹងព្រីង ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានផ្តល់ថវិកាក្នុងការជួយកសាងអគារសិក្សា ចំនួន០៣ខ្នង មាន០៦បន្ទប់ ព្រមទាំងបំពាក់តុ កៅអីគ្រូ-សិស្ស ក្តារខៀន បណ្ណាល័យ ០១បន្ទប់ ឃ្លាំងសម្ភារៈ ០១បន្ទប់ និងបង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាបឋមសិក្សាស្តីធ្វើរ អញ្ចាញ អង្គរ ស្ថិតនៅភូមិអញ្ចាញ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

១-**Mr. Daniel Spitler** ប្រធានមូលនិធិសាលា **Spitler School Foundation** បានផ្តល់ថវិកាចំនួន ១៧.៥០០ ដុល្លារអាមេរិក ។

២-**Mrs. Pam Spitler** អនុប្រធានមូលនិធិសាលា **Spitler School Foundation** បានផ្តល់ថវិកាចំនួន ១៧.៥០០ ដុល្លារអាមេរិក ។

៣-**Mr. Irvin Spitler** សមាជិកមូលនិធិសាលា **Spitler School Foundation** បានផ្តល់ថវិកាចំនួន ១៧.៥០០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ ២០០៩

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៨៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន Mr. KAMITO KEIJI ប្រធានអង្គការ ACSA ដែលបានផ្តល់ថវិកាចំនួន ២៥.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន ០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាចំការអណ្តូង ស្ថិតនៅភូមិចំការអណ្តូង ឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៨៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ជប៉ុន ចំនួន០២រូប ដែលបានឧបត្ថម្ភថវិកាជួយសាងសង់អគារសិក្សា ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់បន្ទប់ នៅក្នុងខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី **TOMIE KUWABARA** ប្រធានអង្គការ **Happy Apple** បានឧបត្ថម្ភថវិកា ចំនួន ២១.៦៦០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា០១ខ្នង មាន០៣បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់បន្ទប់ បង្គន់អនាម័យ០២បន្ទប់ អណ្តូងទឹក០១ ដងទង់ជាតិ០១ ខ្លោងទ្វារ និងផ្លាក ម្ចាស់អំណោយ០១ ជូនដល់សាលាបឋមសិក្សាឈើទាលជ្រុំ ស្ថិតនៅភូមិឈើទាល ឃុំគោល ស្រុកប្រាសាទសំបូរ។

២-លោក **KASHIWA-CITY** និងលោក **IWAMOTO AKIRA** បានឧបត្ថម្ភថវិកាចំនួន ១៧.៧៣៤,៨៥ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា០១ខ្នង មាន០៣បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០៤បន្ទប់ និងអណ្តូងទឹក០១ ជូនដល់សាលាបឋមសិក្សាត្រពាំងក្នុង ស្ថិតនៅឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្ក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានី[illegible] ថ្ងៃទី ០[illegible] [illegible]ក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៨៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនដល់ក្រុមហ៊ុន ÆON Fantasy Co., Ltd. ដែលបានផ្តល់ថវិកា ចំនួន ៣៤.៩០០ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សាចំនួន០១ខ្នង មាន០៤បន្ទប់ សង់ពីបេតុង គ្រោងដំបូលដែក ប្រក់ក្បឿងថៃ ជូនដល់សាលាបឋមសិក្សាមេសាង ស្ថិតនៅភូមិមេសាង ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។ MR

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៨៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន **Ms. MITANI SACHI** ដែលបានផ្តល់ថវិកាចំនួន ៥០.២៩៣ ដុល្លារអាមេរិក តាមរយៈអង្គការ **JHP** ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ សង់ពីបេតុង គ្រោងដំបូលដែក ប្រក់ក្បឿងថៃ ព្រមទាំងបំពាក់គ្រឿងសង្ហារឹម បង្គន់អនាម័យចំនួន០១ មាន០៥បន្ទប់ និង អណ្តូងទឹកចំនួន០១ ជូនដល់អនុវិទ្យាល័យខ្ពបវែង ស្ថិតនៅភូមិខ្ពបវែង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ២០០៩

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៨៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ **Japan Team of Young Human Power (JHP)** ដែលបានផ្តល់ថវិកា ចំនួន ៤២.២៨០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ បង្គន់ ០១ខ្នង មាន០៤បន្ទប់ ធ្វើពីបេតុង ព្រមទាំងបំពាក់គ្រឿងសង្ហារឹម ជូនដល់សាលាបឋមសិក្សាស្គន់ ស្ថិតនៅឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៨៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៥គ្រឿង ជូនអង្គការនិងសប្បុរសជន ដែលបានផ្តល់ថវិកាសរុបចំនួន ៦២.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៦បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់បន្ទប់ បង្គន់អនាម័យចំនួន០៤ ជីកស្រះ ចាក់ដីបំពេញទីធ្លាខាងមុខ និងខាងក្រោយអគារសិក្សា រៀបចំសួនច្បារ និងដាំដើមឈើជូនដល់អនុវិទ្យាល័យបត់ត្រង់ ស្ថិតនៅស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-អង្គការ Samaritan's Purse ប្រចាំប្រទេសអូស្ត្រាលី

២-អង្គការ Samaritan's Purse ប្រចាំព្រះរាជាណាចក្រកម្ពុជា

៣-លោកវេជ្ជបណ្ឌិត **ទៅ ម្ទុមច័ន្ទ** ប្រធានសម្របសម្រួលកម្មវិធីសាលា និងសង្គ្រោះបន្ទាន់

៤-លោក **ម៉ឺុង សារុន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ

៥-លោក **អ៊ុំ ឡុង** អភិបាលស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៨៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគថវិកាជួយកសាងអគារសិក្សា នៅខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

- Ms. TAKAGI ASAKO បានឧបត្ថម្ភថវិកា ចំនួន ១៦.៩៨០ ដុល្លារ តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង និង បំពាក់សម្ភារៈ នៅសាលាបឋមសិក្សាជីស្សារាំរៀវ ក្នុងឃុំកំពង់ចម្លង ស្រុកស្វាយជ្រំ ។

ខ. មេដាយប្រាក់ស្ថាបនាជាតិ :

១-Mr. TONI TITH ជនជាតិអាមេរិកកាំង បានឧបត្ថម្ភថវិកា ចំនួន ៧.០០០ ដុល្លារ
២-Ms. THARY UNG ជនជាតិអាមេរិកកាំង បានឧបត្ថម្ភថវិកា ចំនួន ៧.០០០ ដុល្លារ
៣-Mr. SCOTT MINTEN ជនជាតិអាមេរិកកាំង បានឧបត្ថម្ភថវិកា ចំនួន ៦.៥០០ ដុល្លារ
៤-Mr. NANCY PERONG ជនជាតិអាមេរិកកាំង បានឧបត្ថម្ភថវិកា ចំនួន ៦.៥០០ ដុល្លារ

សប្បុរសជនទាំង០៤រូប បានផ្តល់ថវិកាជួយកសាងបណ្ណាល័យ ០១ខ្នង និងផ្តល់គ្រឿងសម្ភារៈ ជូនសាលាបឋមសិក្សាដូង ក្នុងឃុំដូង ស្រុករមាសហែក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៩០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនសមាគមនិងអង្គការ ដែលបានផ្តល់ថវិកាសរុបចំនួន ៤១.៦៧១ ដុល្លារអាមេរិក ក្នុងការជួយរៀបចំតាក់តែងសៀវភៅកំណាព្យ ពាក្យបណ្តៅ តារាងព្យញ្ជនៈទាំង៣៣តួ និងធ្វើការបោះពុម្ពដើម្បីផ្សព្វផ្សាយអោយគ្រូមត្តេយ្យបានប្រើប្រាស់ទូទាំងប្រទេស សំរាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត/ក្រុង និងស្រុក/ខណ្ឌ ដូចមានរាយនាមខាងក្រោម :-

១-អង្គការគាំពារកុមារខ្មែរ **(Caring for Young Khmer)**

២-សមាគម **Japan's Postal Saving for International Voluntary Aid**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៩១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាសរុបចំនួន ៣១.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារ ចំនួន០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សាអង្គ្រង ស្ថិតនៅឃុំដំណាក់រាំង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មានដូចមានរាយនាមខាងក្រោម :-

១-**Mr. KATO YOSHIO** សប្បុរសជន
២-**Mr. Negishi Tsuneji** ប្រធានសមាគមជួយខ្មែរ នៃសតវត្សទី ២១

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HA

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៩៧ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន **Ms. Kawashima Ai, Mr. Yoshinaga Tatsutoshi and Fans of Ms.Kawashima Ai** ដែលបានផ្ដល់ថវិកាសរុបចំនួន ៣៨.៧៧៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិម ជូនដល់សាលាបឋមសិក្សាច្រាំងខ្ពស់ ស្ថិតនៅភូមិច្រាំងខ្ពស់ ឃុំព្រែកជីក ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] កក្កដា ឆ្នាំ ២០០៩

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៩៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានឧបត្ថម្ភថវិកា ជួយសាងសង់អគារសិក្សាមួយចំនួន នៅស្រុកសំពៅមាស និងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី **MOLIE COLSON** ជនជាតិកាណាដា បានឧបត្ថម្ភថវិកា ចំនួន ៥១.១០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា០២ខ្នង មាន០៩បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០២បន្ទប់ ធ្វើខ្លោងទ្វារ អាងស្តុកទឹក និងកសាងអសនៈដំកល់ព្រះពុទ្ធរូប ១ ។

២-លោកស្រី **KIM KALY** នាយិកាអង្គការ **HOPE** ប្រចាំខេត្តពោធិ៍សាត់ បានឧបត្ថម្ភថវិកា ចំនួន ៥២.៧០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សាឈើ ចំនួន០៦ខ្នង មាន១៧បន្ទប់ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៩៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **INOUE AKIO** ដែលបានផ្តល់ថវិកាចំនួន ៤៤.៣០០ ដុល្លារអាមេរិក តាមរយៈអង្គការ **JHP** ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន ០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ និងបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាសំបុកអក ស្ថិតនៅភូមិសំបុកអក ឃុំកំពង់ព្រៀង ស្រុកសង្កែ ខេត្តបាត់ដំបង ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៩៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនអង្គការ និងសប្បុរសជន ដែលបានផ្តល់ថវិកានិងដីសំរាប់កសាងអគារសិក្សា សាលាបឋមសិក្សា និង អនុវិទ្យាល័យចក ស្ថិតនៅឃុំចក ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

១-**អង្គការនំរទេស្សន៍សង្គ្រោះកុមារកម្ពុជា** SCN បានផ្តល់ថវិកាចំនួន ៦៦.២០៣ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ និងអណ្តូងលូ ១កន្លែង ។

២-លោក **ហុច មើច** និងគ្រួសារព្រមទាំងបុត្រ បានឧបត្ថម្ភជាដីចំនួន ១ហិតា គិតជាប្រាក់មានតម្លៃស្មើ ១៨.០០០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៩៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ១៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង ព្រះវិហារ សាលាធម្មសភា ០១ខ្នង កុដិថ្ម ០១ខ្នង មានពីរជាន់ រោងទទួលភ្ញៀវ ០១ខ្នង ម៉ាស៊ីនភ្លើង របងបេតុងប្រវែង ៤៣៥ម៉ែត្រ បង្គន់អនាម័យ ០១ខ្នង មានពីរបន្ទប់ និងចាក់ដីក្នុងទីធ្លាវត្តនៅវត្តអង្គឡៀលពិសី ឃុំទទុង ស្រុកដងទង់ ខេត្តកំពត ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក‑មេដាយមាសស្ថាបនាជាតិ :

១-	ព្រះតេជគុណ	**ទូន**	**ឆាន់**	ព្រះចៅអធិការវត្តអង្គឡៀលពិសី	បច្ច័យចំនួន ១១.០០០ ដុល្លារ
២-	ព្រះតេជគុណ ពុទ្ធិបណ្ឌិតោ	**គង់**	**សុភ័ក្តិ**	គង់នៅវត្តកំពង់សំបួរខេត្តកណ្តាល	បច្ច័យចំនួន ១០.០០០ ដុល្លារ
៣-	ព្រះតេជគុណ សុរិយវង្សា	**ឯក**	**សុវណ្ណមករា**	គង់នៅវត្តកំពង់សំបួរខេត្តកណ្តាល	បច្ច័យចំនួន ១០.០០០ ដុល្លារ
៤-	លោក	**សុខ**	**យុត**	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកាចំនួន ១០.០០០ ដុល្លារ
៥-	អ្នកស្រី	**លី**	**លីនដា**	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.០០០ ដុល្លារ
៦-	អ្នកស្រី	**លឹម**	**ណៃអេង**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.០០០ ដុល្លារ
៧-	អ្នកស្រី	**អេង**	**ផល្លី**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.០០០ ដុល្លារ
៨-	អ្នកស្រី	**យី**	**ឆៃត្រី**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.០០០ ដុល្លារ

៩- អ្នកស្រី តាំង សៃណោទ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១- លោក ជុំ សុខុន សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ៥.០០០ ដុល្លារ

២- ឧបាសក ម៉ែន ស៊ូ សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ៥.០០០ ដុល្លារ

គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :

១- កញ្ញា ជា នាគ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.០០០ ដុល្លារ

២- អ្នកស្រី ជា ញ៉ី សប្បុរសជនខ្មែរនៅប្រទេសបារាំង ថវិកាចំនួន ១.០០០ ដុល្លារ

៣- ឧបាសិកា ម៉ន ហ៊ឿន សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា

*****

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ ១ ÷

បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល រៀបចំ និងសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង ដែលមានសមាសភាពដូចខាងក្រោម÷

១- ឯកឧត្តម **ជា សុផារ៉ា**	រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ	ប្រធាន
២- ឯកឧត្តម **ឡាក់ ចាម**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	អនុប្រធាន
៣- ឯកឧត្តម **សុខ ចិន្តា**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	អនុប្រធាន
៤- ឯកឧត្តម **សួស គង់**	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិកអចិន្ត្រៃយ៍
៥- ឯកឧត្តម **ម៉ុង សំផន**	រដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
៦- ឯកឧត្តម **ទី ចន្ទ្រំផល**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៧- ឯកឧត្តម **ឆឹក គ្រឿនចុន្ថា**	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៨- ឯកឧត្តម **ជូ យិនស៊ីម**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
៩- ឯកឧត្តម **ឡិម គីមស៊ា**	រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ	សមាជិក
១០- ឯកឧត្តម **ពិត ចំណាន**	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១១- ឯកឧត្តម **លឹម ស៊ីដេនីន**	រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១២- ឯកឧត្តម **ឈី សន់**	អនុរដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម	សមាជិក
១៣- ឯកឧត្តម **ខៀវ ចិសុទ្ធ**	អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១៤- ឯកឧត្តម **ទី សុគន្ធ**	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធាន រដ្ឋបាលព្រៃឈើ	សមាជិក
១៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **គីម ប៊ុនថាន**	នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងជានាយរងសេនាធិការចំរុះនៃអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ	សមាជិក
១៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **ពៅ ឌីថន**	ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែននៃអគ្គស្នងការដ្ឋាននគរបាលជាតិ	សមាជិក
១៧- ឯកឧត្តម **ហេង រតនា**	អគ្គនាយកមជ្ឈមណ្ឌលបោសសំអាតមីនកម្ពុជា	សមាជិក
១៨- ឯកឧត្តម **អ៊ី ឈាន**	អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន	សមាជិក
១៩- ឯកឧត្តម **អ៊ុំ ម៉ារ៉ា**	អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ	សមាជិក
២០- ឯកឧត្តម **ពិច សុខិន**	អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ	សមាជិក
២១- ឯកឧត្តម **អ៊ុង អឿន**	អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ	សមាជិក

ប្រការ ២ ÷

គណៈកម្មការអន្តរក្រសួង មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្តគោលនយោបាយ ផែនការ និងគម្រោងអភិវឌ្ឍការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង ក្នុងលក្ខណៈជាប្រព័ន្ធ និងជាខ្សែសង្វាក់ប្រទាក់ក្រឡាគ្នា។

គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម÷

- រៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាកញ្ចប់ សម្រាប់ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋនៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង នៃព្រះរាជាណាចក្រកម្ពុជា ឱ្យស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្របសម្រាប់ធ្វើការអភិវឌ្ឍ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង
- សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
- ផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្ម័គ្រចិត្ត ទៅតាំងទីលំនៅនៅតំបន់ឱ្យបានច្រើនកុះករ
- ទាក់ទាញឱ្យមានការចូលរួមវិនិយោគពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង។

ប្រការ ៣ ÷

គណៈកម្មការអន្តរក្រសួង ត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងតំណាងដៃគូអភិវឌ្ឍន៍ ចូលរួមប្រជុំតាមការចាំបាច់។

ប្រការ ៤ ÷

គណៈកម្មការអន្តរក្រសួង ត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។ ប្រធានគណៈកម្មការអន្តរក្រសួង អាចស្នើសុំមន្ត្រីពីក្រសួងស្ថាប័នពាក់ព័ន្ធឱ្យមកចូលរួមជាសមាជិកនៃលេខាធិការដ្ឋានតាមការចាំបាច់។

ប្រការ ៥ ÷

គណៈកម្មការអន្តរក្រសួងប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

ប្រការ ៦ ÷

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល÷__
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✽៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ៧៣៤ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩

ប្រកាស

ស្តីពី

ការគ្រប់គ្រង ការរៀបចំរចនាសម្ព័ន្ធចាត់តាំង និងការប្រព្រឹត្ត ទៅ របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៥១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

សម្រេច

ប្រការ ១: បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) ជាគ្រឹះស្ថានសា[illegible]

អាណាព្យាបាលបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រង និងផ្តល់របបសន្តិសុខសង្គម អនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌទីមួយ១ និងបទប្បញ្ញត្តិដែលនៅជាធរមាន។

ប្រការ ២ : ការគ្រប់គ្រង ការរៀបចំរចនាសម្ព័ន្ធចាត់តាំង និងការប្រព្រឹត្តទៅ នៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានអង្គការប្រតិបត្តិ ត្រូវដឹកនាំដោយនាយក និងនាយករងមួយចំនួនតាមការចាំបាច់ និងមានការិយាល័យដូចខាងក្រោម ៖

ថ្នាក់កណ្តាល

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យហិរញ្ញវត្ថុ និងគណនេយ្យ
- ការិយាល័យអធិការកិច្ច
- ការិយាល័យផែនការ ស្ថិតិ និងព័ត៌មានវិទ្យា
- ការិយាល័យតាវកាលិក

ថ្នាក់មូលដ្ឋាន

- ការិយាល័យ **ប.ជ.ស** រាជធានី-ខេត្ត គ្រប់គ្រងដោយប្រធាន អនុប្រធាន និងមានមន្ត្រីជំនាញមួយចំនួនតាមការងារចាំបាច់
- សាខា **ប.ជ.ស** ក្រុង-ស្រុក-ខណ្ឌ គ្រប់គ្រងដោយប្រធាន អនុប្រធាន និងមានមន្ត្រីជំនាញមួយចំនួនតាមការងារចាំបាច់
- ការិយាល័យ **ប.ជ.ស** រាជធានី-ខេត្ត និងសាខា **ប.ជ.ស** ក្រុង-ស្រុក-ខណ្ឌ ត្រូវអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់សិទ្ធិរបស់នាយក **ប.ជ.ស** ។

ប្រការ ៣ : ការិយាល័យរដ្ឋបាល និងបុគ្គលិក មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំលក្ខណៈវិនិច្ឆ័យ និងនីតិវិធីទាក់ទងនឹងការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈឬមុខតំណែង ការដាក់វិន័យ ការផ្តល់លាភការ វាយតម្លៃសម្រាប់វាស់ស្ទង់ស្នាដៃ និងសុខុមាលភាពរបស់មន្ត្រីរាជការ និងបុគ្គលិកនៃ **ប.ជ.ស**
- ចាត់ចែង និងគ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងបុគ្គលិកនៃ **ប.ជ.ស**
- លើកគម្រោងកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស
- រៀបចំសណ្តាប់ធ្នាប់ សន្តិសុខ និងអនាម័យ
- រៀបចំ និងលើកគម្រោងចំណាយប្រចាំថ្ងៃ និងប្រចាំឆ្នាំសម្រាប់ផ្នែករដ្ឋបាល
- រៀបចំ ផ្សព្វផ្សាយគោលនយោបាយ និងសកម្មភាពគ្រប់រូបភាពនៃ **ប.ជ.ស**

- គ្រប់គ្រងទទួលខុសត្រូវរាល់ឯកសារទាំងអស់នៃ **ប.ជ.ស**
- រៀបចំចាត់ចែង និងគ្រប់គ្រងបណ្ណាល័យ
- រៀបចំបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរដ្ឋបាលនៃ **ប.ជ.ស**
- រៀបចំផែនការសម្រាប់ការងាររដ្ឋបាល និងធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ
- ធ្វើរបាយការណ៍សកម្មភាពរួមប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំរបស់ **ប.ជ.ស**។

ប្រការ ៤ : ការិយាល័យហិរញ្ញវត្ថុ និងគណនេយ្យ មានភារកិច្ចដូចខាងក្រោម ៖

- ទទួលបន្ទុកគ្រប់គ្រងហិរញ្ញវត្ថុ និងកាន់កាប់បញ្ជីគណនេយ្យសមស្របតាមគោលការណ៍ និងវិធាន ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ និងលើកគម្រោងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ប.ជ.ស**
- ចាត់ចែងអនុវត្តការប្រមូលចំណូលពីបណ្តាប្រភពផ្សេងៗតាមផែនការដែលបានអនុម័ត
